**ធម្មទេសនារបស់លោកអភិបាលអូលីវីយេ**
**អភិបូជាអភិបូជាចូលឆ្នាំចៀតណាមនៅចំប៉ា**
**ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៨**
*គ្រួសារដ៏វិសុទ្ធ ជាគំរូសម្រាប់គ្រួសារទាំងឡាយ*

អត្ថបទទី១៖ អស ៥៨,១-៩ក
ដំណឹងល្អ៖ មថ ៩,១៤-១៥

បងប្អូនជាទីស្រឡាញ់!

ជូនពរឆ្នាំថ្មី ឲ្យយើងមានសេចក្ដីសុខ ឲ្យយើងមានសុខភាពល្អ ឲ្យយើងចេះរួមរស់ជាក្រុមគ្រួសារតែមួយនៅក្នុងអង្គព្រះយេស៊ូគ្រីស្ត។ យើងចូលអភិបូជាថ្ងៃនេះ ដើម្បីសុំព្រះជាម្ចាស់ប្រទានពរឲ្យយើងទាំងអស់គ្នានៅក្នុងឆ្នាំថ្មីនេះ។ ថ្ងៃនេះមួយនៃពិធីចូលឆ្នាំ ណែនាំឲ្យយើងគោរពព្រះយេស៊ូនៅលើឈើឆ្កាង ទីពីរយើងគោរពព្រះនាងម៉ារី ទីបីយើងគោរពលោកយ៉ូសែប។ ឲ្យព្រះយេស៊ូ ព្រះនាងម៉ារី លោកយ៉ូសែប ការពារថែរក្សាយើងពេញមួយឆ្នាំខាងមុខនេះ ដោយសារយើងជាគ្រីស្តបរិស័ទ យើងបានយកព្រះយេស៊ូដែលបានបូជាព្រះជន្មលើឈើឆ្កាង ជាគំរូជាកម្លាំង ដើម្បីឲ្យយើងរស់នៅក្នុងជីវិតរបស់យើងប្រចាំថ្ងៃ។ យើងបានយកព្រះយេស៊ូជាគំរូ នៅពេលព្រះយេស៊ូលះបង់ចោលអ្វីៗទាំងអស់ ដើម្បីឲ្យយើងទាំងអស់គ្នាទទួលជីវិតដ៏បរិបូរណ៍។ ព្រះអង្គសុខចិត្តសោយទិវង្គតដើម្បីឲ្យយើងមានជីវិត ព្រះយេស៊ូសុខចិត្តលះបង់ចោលអ្វីៗទាំងអស់ដើម្បីឲ្យយើងមានកម្លាំងពេញ ព្រះយេស៊ូបានបង្ហាញសេចក្តីស្រឡាញ់ដ៏ពិតប្រាកដដល់មនុស្សលោក។

ក្នុងគម្ពីរដំណឹងល្អ "**សូមស្រឡាញ់គ្នាទៅវិញទៅមក រួមទាំងសត្រូវរបស់ខ្លួនដែរ**" ពេលយើងយកព្រះយេស៊ូលើឈើឆ្កាងជាគំរូ ពិតមែននៅពេលនោះយើងបានយកព្រះយេស៊ូដែលស្រឡាញ់យើងយ៉ាងពិតប្រាកដ។ ព្រះបន្ទូលចុងក្រោយរបស់ព្រះយេស៊ូនៅលើឈើឆ្កាងថា "**សូមលើកលែងទោសឲ្យគេផង**" គេជាអ្នកដែលសម្លាប់ព្រះអង្គ ព្រះយេស៊ូបានលើកលែងទោសឲ្យគេដើម្បីបង្ហាញពិតមែនសេចក្តីស្រឡាញ់ទូលំទូលាយណាស់ រហូតដល់ព្រះអង្គបានលើកលែងទោសឲ្យសត្រូវដែលសម្លាប់ព្រះអង្គ។

សម្រាប់ឆ្នាំថ្មីនេះ **ឲ្យយើងមើលព្រះយេស៊ូថែមទៀត** យើងធ្វើយ៉ាងណាដើម្បីខិតខំរស់នៅដោយស្រឡាញ់បងប្អូនឯទៀតៗ ទោះបីជាសត្រូវរបស់យើងក៏ដោយ។ ឲ្យព្រះ

សហគមន៍កាតូលិករបស់យើងទៅជាគំរូនៃសេចក្តីស្រឡាញ់នៅក្នុងសង្គម ក្នុងទំនាក់ទំនងជាមួយមនុស្សទាំងអស់គ្រប់ជាតិសាសន៍ ដើម្បីទៅជាគ្រួសារតែមួយ។

**ព្រះសហគមន៍ណែនាំឲ្យយើងគោរពព្រះនាងម៉ារី**នៅក្នុងឆ្នាំថ្មីនេះ ព្រះនាងម៉ារីដែលជាគ្រីស្តទូតមុនគេបង្អស់ ដែលណែនាំឲ្យយើងចូលនៅក្នុងជីវិតគ្រួសាររបស់ព្រះយេស៊ូ។ ព្រះនាងម៉ារីជាម្តាយរបស់យើង ដែលណែនាំឲ្យយើងចង់ធ្វើតាមព្រះនាងម៉ារី យើងធ្វើយ៉ាងណាដើម្បីឲ្យឆ្នាំថ្មីនេះឲ្យជីវិតរបស់យើង យើងយកព្រះនាងម៉ារីជាគំរូដើម្បីរស់នៅតាមរបៀបព្រះនាងម៉ារី។ ព្រះនាងម៉ារីបានស្រឡាញ់កូន ធ្វើតាមកូនជានិច្ច ព្រះនាងម៉ារីបានស្រឡាញ់ព្រះយេស៊ូខ្លាំងណា នៅក្នុងរបៀបស្លូតបូត នៅក្នុងរបៀបយកចិត្តទុកដាក់នៅក្នុងរបៀបដាក់ខ្លួន នៅក្នុងរបៀបបម្រើ នៅក្នុងរបៀបណែនាំឲ្យអ្នកដទៃស្តាប់ព្រះបន្ទូលរបស់ព្រះយេស៊ូតែម្តង។ ដូច្នេះសម្រាប់ឆ្នាំថ្មីនេះ ព្រះនាងម៉ារីបាននិយាយមកយើងទាំងអស់គ្នាថា "**សូមស្តាប់កូនរបស់ខ្ញុំនិងធ្វើតាមគាត់នៅក្នុងឆ្នាំថ្មីនេះ ឲ្យចេះស្រឡាញ់ចេះគោរពគ្នាទៅវិញទៅមក**"។

**ព្រះសហគមន៍ណែនាំឲ្យយើងមើលសន្តយ៉ូសែប** ដែលជាមនុស្សដ៏សុចរិតមុនគេបង្អស់ ជាមូលហេតុព្រះជាម្ចាស់បានជ្រើសរើសគាត់ ដើម្បីឲ្យគាត់យកព្រះនាងម៉ារីជាភរិយា និងធ្វើជាឪពុករបស់ព្រះយេស៊ូនៅក្នុងគ្រួសារដ៏វិសុទ្ធ។ លោកយ៉ូសែប បានយកចិត្តទុកដាក់ជាមួយប្រពន្ធ យកចិត្តទុកដាក់ដោយចិញ្ចឹមគ្រួសារ យកចិត្តទុកដាក់ធ្វើឲ្យគ្រួសារមានសេចក្តីសុខ យកចិត្តទុកដាក់ដើម្បីឲ្យគ្រួសាររីកចម្រើន យកចិត្តទុកដាក់អប់រំកូន...។ ដូច្នេះពេលយើងមើលលោកយ៉ូសែប ឲ្យយើងយកសន្តយ៉ូសែបជាគំរូ ដោយសារបើឪពុកមិនយកចិត្តទុកដាក់ធ្វើយ៉ាងណាដើម្បីឲ្យគ្រួសារមានសេចក្តីសុខ។

នៅក្នុងឆ្នាំនេះ យើងមើលគ្រួសារដ៏វិសុទ្ធបានណែនាំឲ្យយើងទទួលព្រះពរសម្រាប់ឆ្នាំថ្មីនេះ។ ព្រះយេស៊ូ ព្រះនាងម៉ារី លោកយ៉ូសែប ណែនាំឲ្យគ្រួសារយើងទាំងអស់នៅក្នុងព្រះសហគមន៍កម្ពុជាទាំងមូល ឲ្យគ្រួសារនីមួយៗយកចិត្តទុកដាក់ ដើម្បីបង្កើតបរិយាកាសនៃសេចក្តីស្រឡាញ់។ នៅក្នុងរដូវ៤០ថ្ងៃនេះ ឲ្យយើងយកចិត្តទុកដាក់អធិដ្ឋានជាលក្ខណៈគ្រួសារ សូមលោកបូជាចារ្យ បងប្រុសបងស្រី ចែកព្រះបន្ទូលដល់ក្រុមគ្រួសារមួយអាទិត្យម្តង យើងអង្គុយជុំគ្នាជាមួយគ្រួសារយើង ដើម្បីអានព្រះបន្ទូលរបស់ព្រះជា

ម្ចាស់ ដើម្បីគិតខ្លួនឯងថា តើព្រះបន្ទូលនេះបានណែនាំឲ្យគ្រួសាររបស់ខ្ញុំដូចម្ដេច? ណែនាំឲ្យខ្ញុំបង្កើតសេចក្ដីស្រឡាញ់ថ្មីដូចម្ដេច? ណែនាំឲ្យខ្ញុំមានកម្លាំងដូចម្ដេច? ឆ្នាំនៃគ្រួសារត្រូវតែជាឆ្នាំនៃសេចក្ដីសុខសម្រាប់គ្រួសារនីមួយៗ យើងដឹងថាឧបសគ្គមាន បញ្ហាយើងមាន ទុក្ខលំបាកយើងមាន ប៉ុន្តែនៅពេលយើងផ្ញើជីវិតទៅលើព្រះជាម្ចាស់ នៅពេលយើងទីពឹងទៅលើព្រះជាម្ចាស់ នៅពេលយើងទីពឹងទៅលើក្រុមគ្រួសារដ៏វិសុទ្ធ យើងអាចទទួលកម្លាំងដើម្បីទៅមុខ ដើម្បីកសាងគ្រួសាររបស់យើងតាមរបៀបព្រះនាងម៉ារី សន្តយ៉ូសែប និងព្រះយេស៊ូ។

ថ្ងៃនេះខ្ញុំអធិដ្ឋាន សម្រាប់ព្រះសហគមន៍របស់យើងទាំងអស់ សម្រាប់បងប្អូនទាំងអស់ សម្រាប់ក្រុមគ្រួសារទាំងអស់យើងអធិដ្ឋាន ដើម្បីឲ្យយើងរួមគ្នាសម្លឹងមើលព្រះនាងម៉ារី សន្តយ៉ូសែប និងព្រះយេស៊ូដើម្បីបង្កើតក្រុមគ្រួសារដ៏សុខសាន្ត ដើម្បីឲ្យឆ្នាំនេះទៅជាឆ្នាំដែលពោរពេញដោយសេចក្ដីសុខសាន្ត ពោរពេញដោយសេចក្ដីស្រឡាញ់ នៅក្នុងក្រុមគ្រួសាររបស់យើងទាំងអស់គ្នា។ នៅពេលក្រុមគ្រួសាររបស់យើងមានសេចក្ដីសុខ ព្រះសហគមន៍របស់យើងមានសេចក្ដីសុខ នៅពេលក្រុមគ្រួសាររបស់យើងមានសេចក្ដីសុខ សង្គមរបស់យើងមានសេចក្ដីសុខដែរ។ ដូច្នេះឆ្នាំនេះ ឲ្យយើងយកចិត្តទុកដាក់ដើម្បីឲ្យគ្រួសាររបស់យើងឈ្នះទុក្ខលំបាក ឈ្នះឧបសគ្គដើម្បីរកឃើញសេចក្ដីសុខយ៉ាងពិតប្រាកដ។ យើងអធិដ្ឋាន យើងទូលអង្វរព្រះជាម្ចាស់ សូមព្រះអង្គប្រទានពរឲ្យគ្រួសារទាំងអស់ ដោយព្រះនាមព្រះបិតា ព្រះបុត្រា ព្រះវិញ្ញាណដ៏វិសុទ្ធ។ អាម៉ែន៕

ជយោ! ឆ្នាំថ្មី